**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ** ៦៥៣/០៨ **គ.ជ.ប**

# សេចក្តីណែនាំ

## ស្តីពី

## ការផ្ទេរសិទ្ធិជូនមេធាវី ឬតំណាងដើមបណ្តឹង ឬចុងចម្លើយ សម្រាប់ការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ឆ្នាំ ២០០៨

អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ព្រមទាំងបទបញ្ជា និង នីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមណែនាំដល់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត (គខ/កប) គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) និងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតទាំងអស់ ស្តីពីការផ្ទេរសិទ្ធិជូនមេធាវី ឬតំណាងដើមបណ្តឹង ឬចុងចម្លើយ ដូចខាងក្រោម ៖

១. ដើម្បីប្រគល់សិទ្ធិជូនមេធាវី ឬតំណាងរបស់ខ្លួន ដើមបណ្តឹង ឬចុងចម្លើយត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរប្រគល់សិទ្ធិជូនមេធាវី ឬតំណាង ដោយមានចុះហត្ថលេខា ឬផ្តិតមេដៃ និងត្រូវមានការយល់ព្រមចុះហត្ថលេខា និង ប្រថាប់ត្រាពីមេធាវី ឬស្នាមមេដៃនៃអ្នកតំណាងនោះផង (អ្នកតំណាងត្រូវតែជានីតិជន) ។

២. លិខិតប្រគល់សិទ្ធិជូនមេធាវី ឬតំណាង ត្រូវផ្ញើជូនក្រុមប្រឹក្សាជំនុំជម្រះ ឬ ក្រុមប្រឹក្សាប្រជុំផ្សះផ្សាយ៉ាងតិចពីរ (២) ម៉ោង មុនពេលបើកសវនាការ ឬប្រជុំសម្រេច ។

៣. លិខិតប្រគល់សិទ្ធិក្នុងមួយករណី មានសុពលភាពប្រើប្រាស់បានតែករណីមួយនោះតែប៉ុណ្ណោះ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សង្ឃឹមយ៉ាងមុតមាំថា គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់ថ្នាក់ និងគណបក្សនយោបាយទាំងអស់ យកចិត្តទុកដាក់ផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងអនុវត្តឱ្យមានប្រសិទ្ធភាព ។

ភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨
**គ.ប. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**អគ្គលេខាធិការ**

តេព នីថា